**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាឧទ្ធរណ៍ភ្នំពេញ**
សំណុំរឿងព្រហ្មទណ្ឌ
លេខ ៣៧៥/៣០-៤-២០១២
សាលដីកា
លេខ ២៩ ក្រ.ណ/២៦-៤-១៣

# **តាងនាមប្រជារាស្ត្រខ្មែរ**
# **សាលាឧទ្ធរណ៍ភ្នំពេញ**

បង្កើតឡើងតាមច្បាប់ស្តីពីការចាត់តាំង និងសកម្មភាពរបស់សាលាជម្រះក្តីដែលប្រកាសឲ្យប្រើតាមក្រឹត្យលេខ ០៦ ក្រ ចុះថ្ងៃទី ០៨-០២-១៩៩៣ បានបើកសវនាការជាសាធារណៈនៅសាលាឧទ្ធរណ៍នាថ្ងៃទី ០៨-៤-២០១៣ ដែលមានសមាសភាពដូចខាងក្រោម ៖

<u>ក្រុមប្រឹក្សាជំនុំជម្រះ</u>

លោក [redacted] ជាប្រធាន
លោក [redacted] ជាចៅក្រមប្រឹក្សា
លោកស្រី [redacted] ជាចៅក្រមប្រឹក្សា

<u>តំណាងមហាអយ្យការ</u>

ឯកឧត្តម [redacted] អគ្គព្រះរាជអាជ្ញា

<u>ក្រឡាបញ្ជីសវនាការ</u>

លោក ទី ចិត្តត្រា

ដើម្បីជំនុំជម្រះលើសំណុំរឿងព្រហ្មទណ្ឌលេខ ៣៧៥ ចុះថ្ងៃទី៣០-៤-២០១២ របស់សាលាឧទ្ធរណ៍ ដែលមាន ៖

-ជនជាប់ចោទឈ្មោះ [redacted] សារ៉េន ភេទប្រុស អាយុ ៣២ ឆ្នាំ ជាតិខ្មែរ មុខរបរកម្មករសំណង់ កើតនៅភូមិ [redacted] ទីលំនៅមុនពេលចាប់ខ្លួន នៅ [redacted] ឪពុកឈ្មោះ [redacted] "ស" ម្តាយឈ្មោះ [redacted] "រ" នៅលីវ ពីមុនធ្លាប់ជាប់ពន្ធនាគាររយៈពេល ៥ (ប្រាំ) ឆ្នាំ ពីបទ ចោរកម្ម ចេញពីពន្ធនាគារនៅឆ្នាំ ២០១០ (ប្តឹងឧទ្ធរណ៍) ។

ឃុំខ្លួននៅពន្ធនាគារព្រៃ ស (ម១) តាមដីកាបង្គាប់ឲ្យឃុំខ្លួនលេខ ៦៦៥ តព្រ ចុះថ្ងៃទី ២៣ ខែ មីនា ឆ្នាំ ២០១១ របស់សាលាដំបូងរាជធានីភ្នំពេញ ។

មានលោក [redacted] សុគន្ធ ជាមេធាវីការពារក្តី ។

១៦៤

ជាប់ចោទពីបទ៖ កំហែងយកដោយប្រើប្រាស់អាវុធ ប្រព្រឹត្តនៅចំណុចមុខផ្ទះលេខ ១៥Eo, ១៧Eo ផ្លូវលេខ ៦៧ ភូមិ ១ សង្កាត់ផ្សារថ្មី ២ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កាលពីថ្ងៃទី ១០-៧-២០១០ ។ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៣៦៣, ៣៦៦ នៃក្រមព្រហ្មទណ្ឌ។

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ភេទស្រី អាយុ ៤២ ឆ្នាំ ជាតិខ្មែរ ទីលំនៅ [redacted]

ឯរឿងហេតុមានដូចតទៅ

**សកម្មភាព**ប្រព្រឹត្តរបស់ជនជាប់ចោទមានដូចតទៅ ៖

កាលពីថ្ងៃទី ១០-៧-២០១០ វេលាម៉ោង ១៦.៣០ នាទី ឈ្មោះ [redacted] លីមធី និងប្តីបានត្រឡប់មកពីផ្សារអូរឬស្សីមកផ្ទះលេខ ១៥Eo,១៧Eo ផ្លូវលេខ ៦៧ ភូមិ ១ សង្កាត់ផ្សារថ្មី ២ ខណ្ឌដូនពេញ រាជធានីភ្នំពេញ ។ ពេលមកដល់មុខផ្ទះបានប្រហែល ៣ នាទី ស្រាប់តែមានជនល្មើសមួយក្រុមមានគ្នា ៣ នាក់ ដកកាំភ្លើងខ្លីភ្ជង់លើជនរងគ្រោះប្លន់យកប្រាក់អស់ចំនួន ១០ (ដប់) លានរៀល រួចរត់ឡើងជិះម៉ូតូគេចខ្លួនបាត់ ហើយក្រោយមកសមត្ថកិច្ចស្រាវជ្រាវចាប់ខ្លួនជនល្មើសបានកសាងសំណុំរឿងបញ្ជូនមកតុលាការ ។

**បានឃើញ**សាលក្រមព្រហ្មទណ្ឌលេខ ០៦ "កប៥" ចុះថ្ងៃទី២១-០២-២០១២ របស់សាលាដំបូងរាជធានីភ្នំពេញ ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅ ៖

១-កែប្រែបទចោទប្រកាន់លើឈ្មោះ [redacted] សារ៉េន ពីបទ កំហែងយកដោយប្រើប្រាស់អាវុធតាមមាត្រា ៣៦៣ និងមាត្រា ៣៦៦ នៃក្រមព្រហ្មទណ្ឌ មកជាបទ អំពើលួចស្ថានទម្ងន់ដោយការប្រព្រឹត្តអំពើហិង្សា និងប្រើប្រាស់អាវុធខុសច្បាប់ តាមមាត្រា ៣៥៣ និងមាត្រា ៣៥៧ នៃក្រមព្រហ្មទណ្ឌ និងមាត្រា ២០ នៃច្បាប់ស្តីពីការគ្រប់គ្រងអាវុធគ្រឿងផ្ទុះ និងគ្រាប់រំសេវ ។

២-ផ្តន្ទាទោសឈ្មោះ [redacted] **សារ៉េន** ភេទប្រុស អាយុ ៣២ ឆ្នាំ ជាតិខ្មែរ ដាក់ពន្ធនាគារកំណត់ចំនួន ០៦ (ប្រាំមួយ) ឆ្នាំ និងពិន័យជាប្រាក់ចំនួន ២.០០០.០០០ (ពីរលាន) រៀល ពីបទអំពើលួចស្ថានទម្ងន់ដោយការប្រព្រឹត្តអំពើហិង្សា និងប្រើប្រាស់អាវុធខុសច្បាប់ ប្រព្រឹត្តនៅចំណុចមុខផ្ទះលេខ ១៥Eo,១៧Eo ផ្លូវលេខ ៦៧ ភូមិ ១ សង្កាត់ផ្សារថ្មី ២ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កាលពីថ្ងៃទី ១០-៧-២០១០ ។ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៣៥៣ និងមាត្រា ៣៥៧ នៃក្រមព្រហ្មទណ្ឌ និងមាត្រា ២០ នៃច្បាប់ស្តីពីការគ្រប់គ្រងអាវុធគ្រឿងផ្ទុះ និងគ្រាប់រំសេវ ។

៣-សាលក្រមនេះជំនុំជម្រះនៅថ្ងៃទី ១៤-០២-២០១២ និងប្រកាសជាសាធារណៈនៅថ្ងៃទី ២១-០២-២០១២ ចំពោះមុខជនជាប់ចោទ, មេធាវីការពារជនជាប់ចោទ ។

បើកផ្លូវប្តឹងឧទ្ធរណ៍ក្នុងកំណត់ច្បាប់ ។

១៦៤

**បានឃើញ**ពាក្យបណ្តឹងឧទ្ធរណ៍លេខ ១៩១ ចុះថ្ងៃទី ២១-៣-២០១២ របស់ជនជាប់ចោទឈ្មោះ [redacted] សារ៉េន ប្តឹងឧទ្ធរណ៍និងសាលក្រមព្រហ្មទណ្ឌលេខ ០៦ "កប៥" ចុះថ្ងៃទី២១-០២-១២ របស់សាលាដំបូងរាជធានីភ្នំពេញ លើចំណុចនៃសេចក្តីសម្រេចទាំងមូល ។

**បានឃើញ**របាយការណ៍រឿង ចុះថ្ងៃទី ២០-៨-២០១២ របស់ចៅក្រមរបាយការណ៍សាលាឧទ្ធរណ៍ ។

**បានឃើញ**សេចក្តីសន្និដ្ឋាន ចុះថ្ងៃទី១៨-១២-២០១២ របស់តំណាងមហាអយ្យការអមសាលាឧទ្ធរណ៍ ។

<u>នាពេលសវនាការ</u>

-ប្រធានក្រុមប្រឹក្សាអានសង្ខេបរបាយការណ៍រឿង

-ជនជាប់ចោទឈ្មោះ [redacted] **សារ៉េន** ឆ្លើយថា មូលហេតុដែលខ្លួនប្តឹងឧទ្ធរណ៍មកនេះ គឺចង់ឲ្យតុលាការបន្ធូរបន្ថយទោសដល់ខ្លួន ។ កាលពីលើកមុនខ្លួនបានចូលរួមលួចគេមែន ប៉ុន្តែចំពោះសំណុំរឿងនេះ ខ្លួនមិនបានចូលរួមប្រព្រឹត្តដូចការចោទប្រកាន់ទេ តែខ្លួនបានជិះម៉ូតូដើរលេងជាមួយពួកគេ មានម៉ូតូ ២ គ្រឿង ជិះគ្នា ៤ នាក់ មួយគ្រឿងម៉ាកសង់, មួយគ្រឿងម៉ាកវីវ៉ា ។

លុះពេលជិះបានមួយសន្ទុះ ស្រាប់តែអ្នកជិះម៉ូតូសង់ប្រាប់ថា មានការបន្តិចក៏ជិះទៅមុនបាត់ទៅ ហើយរយៈពេលប្រហែល ១៥ នាទី ក្រោយមក ទើបខ្លួនទៅដល់ ឃើញគេឆោឡោនៅកន្លែងកើតហេតុ តែមិនដឹងថា មានរឿងអ្វីទេ រួចក៏ជិះម៉ូតូហួសទៅ ។ ក្រោយមកប្រហែល ២សប្តាហ៍ ពួកគេបានឲ្យប្រាក់ខ្លួនចំនួន ១.០០០.០០០ រៀល តែខ្លួនមិនដឹងថា ប្រាក់នោះបានមកដោយសារអំពើប្លន់ឡើយ ។ ពេលជិះម៉ូតូដើរលេងនោះ គឺខ្លួនជិះក្រោយគេ រីឯបក្សពួកខ្លួនជិះទៅមុនបាត់ ។

ពេលគេធ្វើសកម្មភាពប្លន់នោះ ខ្លួនមិនបានឃើញទេ តែពេលខ្លួនជិះទៅដល់កន្លែងកើតហេតុ ទើបឃើញមានការផ្អើលឆោឡោ ។ ចំពោះកាំភ្លើងនោះ គឺពួកគេយកមកដាក់នៅប្រឡោះផ្ទះរបស់ខ្លួន ពេលដែលខ្លួនអង្គុយលើម៉ូតូខាងក្រោយ ។ ខ្លួនមិនចេះបាញ់កាំភ្លើងទេ ។ ខ្លួនធ្លាប់ជាប់ពន្ធនាគារលើកមុនពីបទ លួច។ នៅថ្ងៃកើតហេតុនោះ មុនដំបូងឈ្មោះ វ៉ៃ បានជួបជុំគ្នានៅកន្លែងម៉ុងឌីយ៉ាល ហើយក៏បបួលគ្នាជិះម៉ូតូដើរលេង ដោយមានម៉ូតូ ២ គ្រឿង គឺមួយគ្រឿងជិះទៅមុខឯម៉ូតូខ្លួនជិះតាមក្រោយឆ្ងាយពីគ្នា មិនបានឃើញពួកគេធ្វើសកម្មភាពប្លន់ទេ ។ ខ្លួនសំណូមពរសុំឲ្យតុលាការបន្ធូរបន្ថយទោសដើម្បីឆាប់បានចេញមកមើលថែម្តាយចាស់នៅផ្ទះ ។

-តំណាងមហាអយ្យការសន្និដ្ឋានថា បណ្តឹងឧទ្ធរណ៍របស់ជនជាប់ចោទធ្វើឡើងត្រឹមត្រូវតាមទម្រង់ច្បាប់ យោងតាមមាត្រា ៣៨២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ហើយជនជាប់ចោទក៏បានឆ្លើយសារភាពថា បានចូលរួមធ្វើដំណើរជាមួយពួកគេមែន តែមិនបានចូលរួមធ្វើសកម្មភាពប្លន់ទេ តែបានទទួលប្រាក់ដែលបានមកពីអំពើប្លន់នោះ។ តាមអំណានចម្លើយដើមបណ្តឹងដែលជាជនរងគ្រោះបានបង្ហាញថា ជនជាប់ចោទដែលបានប្រព្រឹត្តអំពើល្មើសនោះ មានគ្នា ៤ នាក់ ដូចការលើកឡើងរបស់ជនជាប់ចោទនៅពេលសវនាការនេះ ដូច្នេះឃើញថា ជនជាប់ចោទឈ្មោះ [redacted] សារ៉េ

មានពាក់ព័ន្ធនឹងបទ លួចដោយប្រើហឹង្សា ហើយសាលាដំបូងបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៦ ឆ្នាំ ឃើញថា ធ្ងន់ដែរ តែជនជាប់ចោទរូបនេះ ពីមុនធ្លាប់ប្រព្រឹត្តអំពើប្លន់ម្តង លុះពេលចេញពីពន្ធនាគារមកក៏ប្រព្រឹត្តអំពើប្លន់ទៀត ដូច្នេះ ការសម្រេចផ្តន្ទាទោសរបស់សាលាដំបូងមានលក្ខណៈសមល្មមហើយ សូមឲ្យតម្កល់សាលក្រមទុកជាបានការ ។

-លោក [redacted] សុគង់ ជាមេធាវីការពារជនជាប់ចោទសន្និដ្ឋានថា កូនក្តីខ្លួនមិនបានចូលរួមធ្វើសកម្មភាពដូចការចោទប្រកាន់នោះទេ ដោយសារឈ្មោះ វ៉ៃ ទូរស័ព្ទហៅកូនក្តីខ្លួននោះ គឺមិនបានប្រាប់ថា ឲ្យមកចូលរួមធ្វើសកម្មភាពប្លន់ ឬឆក់ទេ ហើយពេលកូនក្តីខ្លួនមកជួបជុំគ្នានោះឈ្មោះ វ៉ៃ ប្រាប់ថា ជិះម៉ូតូដើរលេង ដោយមិនបាននិយាយអំពីគម្រោងទៅប្លន់ ឬឆក់ឡើយ ពេលជិះម៉ូតូដើរលេងនោះ មានម៉ូតូ ២ គ្រឿង ជិះគ្នា ៤ នាក់ មួយគ្រឿងម៉ាកសង់, មួយគ្រឿងម៉ាកវីវ៉ា ។ ពេលជិះបានមួយសន្ទុះ ស្រាប់តែអ្នកជិះម៉ូតូសង់ប្រាប់ថា មានការបន្តិចក៏ជិះទៅមុនបាត់, រយៈពេលប្រហែល ១៥ នាទី ក្រោយមក ទើបកូនក្តីខ្លួនទៅដល់ឃើញគេឆោឡោនៅកន្លែងកើតហេតុ តែមិនដឹងរឿងអ្វីទេ ហើយក៏ជិះម៉ូតូហួសទៅ ។ ចំពោះការឲ្យប្រាក់កូនក្តីខ្លួន ១.០០០.០០០ រៀល នោះ កូនក្តីខ្លួនមិនបានដឹងថា ជាប្រាក់ដែលបានមកពីអំពើប្លន់ទេ ហេតុដូច្នេះ ក្នុងនាមខ្លួនជាមេធាវីការពារសិទ្ធិជនជាប់ចោទសំណូមពរសុំឲ្យក្រុមប្រឹក្សាមេត្តាកែប្រែពីបទ លួចដោយប្រើអំពើហឹង្សា មកជាបទទទួលផលចោរកម្ម តាមមាត្រា ៣៩៩ នៃក្រមព្រហ្មទណ្ឌ ។

-ក្រោយពីបានស្តាប់អំណានរបាយការណ៍រឿង

-ក្រោយពីបានស្តាប់ចម្លើយរបស់ជនជាប់ចោទ

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីជនជាប់ចោទ

-ក្រោយពីបានពិនិត្យភស្តុតាងដែលពាក់ព័ន្ធនឹងរឿងក្តី

-ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

<u>សាលាឧទ្ធរណ៍យល់ឃើញថា</u>

១-ពាក្យបណ្តឹងឧទ្ធរណ៍លេខ ១៩១ ចុះថ្ងៃទី ២១-៣-២០១២ របស់ជនជាប់ចោទឈ្មោះ [redacted] សារ៉េន ប្តឹងឧទ្ធរណ៍នឹងសាលក្រមព្រហ្មទណ្ឌលេខ ០៦ "កប៥" ចុះថ្ងៃទី ២១-០២-២០១២ របស់សាលាដំបូងរាជធានីភ្នំពេញ ត្រង់ចំណុចទាំងមូលនៃសេចក្តីសម្រេច បានធ្វើឡើងត្រឹមត្រូវតាមកំណត់ច្បាប់ យោងតាមមាត្រា ៣៧៣, មាត្រា ៣៧៥, មាត្រា ៣៧៦ និងមាត្រា ៣៨២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ដែលអាចឲ្យសាលាឧទ្ធរណ៍ទទួលយកសំណុំរឿងព្រហ្មទណ្ឌលេខ ៣៧៥ ចុះថ្ងៃទី ៣០-៤-២០១២ របស់សាលាឧទ្ធរណ៍ មកធ្វើការជំនុំជម្រះបាន ។

២-ជនជាប់ចោទឈ្មោះ [redacted] សារ៉េន បានឆ្លើយថា ខ្លួនពិតជាបានជិះម៉ូតូជាមួយមិត្តភ័ក្ររបស់ឈ្មោះ វ៉ៃ, ពេលជិះម៉ូតូដល់កន្លែងកើតហេតុ ខ្លួនឃើញគ្នារបស់ខ្លួនដែលជិះម៉ូតូម៉ាកវីវ៉ាបានយកកាបូបលុយរបស់ជនរងគ្រោះរត់ឡើងម៉ូតូ រួចជិះគេចខ្លួន ហើយម្នាក់ដែលឌុបខ្លួនបានបើក

ម៉ូតូតាមពីក្រោយចម្ងាយ ៥០ ម៉ែត្រ ពីគ្នា ខណៈនោះ ម្នាក់ដែលឌុបខ្លួនបានយកកាំភ្លើងមិនស្គាល់ម៉ាកមកដាក់លើភ្លៅខ្លួន ។ ក្រោយថ្ងៃកើតហេតុ ២ ថ្ងៃ ឈ្មោះ វៃ បានទូរស័ព្ទហៅខ្លួនឲ្យទៅយកប្រាក់ជាង មួយលានរៀល ។ ខ្លួនគ្មានគោលបំណងចូលរួមប្លន់ទេ គឺខ្លួនគ្រាន់តែបានជិះម៉ូតូជាមួយមិត្តភ័ក្ររបស់ឈ្មោះ វៃ ប៉ុណ្ណោះ ។ ចម្លើយនេះ ជាចម្លើយដែលឆ្លើយដោះសារតែប៉ុណ្ណោះ ព្រោះថាបើជនជាប់ចោទពុំមែនជាបក្សពួករបស់ឈ្មោះ វៃ ទេ នោះច្បាស់ជាឈ្មោះ វៃ និងមិត្តភ័ក្រមិនឌុបជនជាប់ចោទទៅធ្វើសកម្មភាពជាមួយ និងដកកាំភ្លើងដាក់លើភ្លៅជនជាប់ចោទពេលជិះតេចខ្លួនទេ ហើយពេលធ្វើសកម្មភាពរួច ច្បាស់ជាឈ្មោះ វៃ មិនឲ្យប្រាក់ជនជាប់ចោទឡើយ ។

៣-ជនជាប់ចោទ ពិតជាបានចូលរួមធ្វើសកម្មភាពចាប់យកកាបូបជនរងគ្រោះ ដោយប្រើប្រាស់អាវុធជាមួយបក្សពួកប្រាកដមែន ដែលអំពើនេះ គឺជាបទល្មើស លួច ។ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៣៥៣ និងមាត្រា ៣៥៧ នៃក្រមព្រហ្មទណ្ឌ និងមាត្រា ២០ នៃច្បាប់ស្តីពីការគ្រប់គ្រងអាវុធជាតិផ្ទុះ និងគ្រាប់រំសេវ ។

៤-មានពិរុទ្ធភាពគ្រប់គ្រាន់លើឈ្មោះ [redacted] សារ៉េន ពីបទ លួច ប្រព្រឹត្តនៅចំណុចមុខផ្ទះលេខ ១៥ Eo, ១៧Eo ផ្លូវលេខ ៦៧ ភូមិ ១ សង្កាត់ផ្សារថ្មី២ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កាលពីថ្ងៃទី ១០-៧-២០១០ ។ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៣៥៣, មាត្រា ៣៥៧ នៃក្រមព្រហ្មទណ្ឌ និងមាត្រា ២០ នៃច្បាប់ស្តីពីការគ្រប់គ្រងអាវុធជាតិផ្ទុះ និងគ្រាប់រំសេវ ។

៥-សំអាងហេតុ និងសេចក្តីសម្រេចក្នុងសាលក្រមព្រហ្មទណ្ឌលេខ ០៦ "កប៥" ចុះថ្ងៃទី ២១-០២-២០១២ របស់សាលាដំបូងរាជធានីភ្នំពេញ មានមូលហេតុត្រឹមត្រូវ គប្បីសាលាឧទ្ធរណ៍ចេញសាលដីកាតម្កល់សាលក្រមនេះ ទុកជាបានការទាំងមូល ។

៦-តំណាងមហាអយ្យការធ្វើសេចក្តីសន្និដ្ឋានថា សុំឲ្យក្រុមប្រឹក្សាសម្រេចតម្កល់សាលក្រមរបស់សាលាដំបូងរាជធានីភ្នំពេញ ទុកជាបានការ ។

៧-មេធាវីការពារសិទ្ធិជនជាប់ចោទធ្វើសេចក្តីសន្និដ្ឋានថា កូនក្តីខ្លួនមិនបានធ្វើសកម្មភាពដូចការចោទប្រកាន់ទេ គ្រាន់តែបានទទួលប្រាក់ដែលបានមកពីអំពើលួចតែប៉ុណ្ណោះ ដូច្នេះ សុំឲ្យក្រុមប្រឹក្សាកែប្រែបទចោទប្រកាន់មកជាបទល្មើស ទទួលផលចោរកម្ម ។

៨-ជនជាប់ចោទនិយាយសម្តីចុងក្រោយថា សុំឲ្យក្រុមប្រឹក្សាមេត្តាបន្ធូរបន្ថយទោស ។

ហេតុដូច្នេះ

វិនិច្ឆ័យសេចក្តី

១-ទទួលពាក្យបណ្តឹងឧទ្ធរណ៍លេខ ១៩១ ចុះថ្ងៃទី ២១-៣-២០១២ របស់ជនជាប់ចោទឈ្មោះ [redacted] សារ៉េន ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែបដិសេធចោលដោយផ្ទុយនឹងគតិច្បាប់ ។

២-តម្កល់សាលក្រមព្រហ្មទណ្ឌលេខ ០៦ "កប៥" ចុះថ្ងៃទី ២១-១២-២០១២ របស់សាលាដំបូងរាជធានីភ្នំពេញ ទុកជាបានការ ។

៣-បន្តការឃុំខ្លួនជនជាប់ចោទតាមច្បាប់ ។

៤-សាលដីកានេះជំនុំជម្រះ នៅថ្ងៃទី ០៨-៤-២០១៣ ចំពោះមុខជនជាប់ចោទ, មេធាវីការពារសិទ្ធិជនជាប់ចោទ និងប្រកាសជាសាធារណៈ នៅថ្ងៃទី ២៦-៤-២០១៣ ចំពោះមុខជនជាប់ចោទ។

ទុកសិទ្ធិឲ្យប្តឹងសាទុក្ខតាមកំណត់ច្បាប់ ៕

**សេចក្តីនេះ ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ទ្រង់ត្រាស់បង្គាប់មកមន្ត្រីទទួលបន្ទុកអនុវត្តសាលដីកា ស្ថាប័នមានសមត្ថកិច្ចគ្រប់ថ្នាក់ គ្រប់តំណែង និងកងកម្លាំងប្រដាប់អាវុធជួយសហការអនុវត្តសាលដីកានេះឲ្យបានសម្រេច ប្រសិនបើមានសំណូមពរត្រឹមត្រូវតាមច្បាប់ ។**

| ក្រឡាបញ្ជី | ចៅក្រមប្រឹក្សា | ប្រធានក្រុមប្រឹក្សាជំនុំជម្រះ |
|---|---|---|
| ហត្ថលេខា [redacted] | ហត្ថលេខា [redacted], [redacted] | ហត្ថលេខា [redacted] |

---

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម

ភ្នំពេញ ថ្ងៃទី 11 ខែ 12 ឆ្នាំ ២០១៤

ក្រឡាបញ្ជី

[redacted]

បានឃើញ

ប្រធានសាលាឧទ្ធរណ៍

[redacted]